ចកស្រង់ចេញពីសៀវភៅ **"ជីវិតបរិសុទ្ធ"** – សៀវភៅសំរាប់ហ្វឹកហ្វឺននៃព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត សហការជាមួយស្ថាប័នហ្វឹកហ្វឺនជាតិ (Nations Training Institue) ព័ត៌មាននេះអាចរកឃើញ នៅទំព័រទី ៣៤ ដល់ ទំព័រទី ៣៧ *(ទំព័រទាំងនេះសំរាប់តែ សៀវភៅភាសាខ្មែរប៉ុណ្ណោះ)* ***(ព្រះពុទ្ធទំនាយអំពីព្រះយេស៊ូ)*** ។

---

**សាសនាព្រះពុទ្ធ :** ពុទ្ធសាសនិកជឿថា មនុស្សត្រូវធ្វើបុណ្យដើម្បីអោយមានជីវិតល្អ ទៅថ្ងៃខាងមុខ ពួកគេដឹងថា មនុស្សមានបាប ដូច្នេះមនុស្សម្នាក់ៗព្យាយាមធ្វើបុណ្យ ដើម្បីបិទបាំងអំពើបាបរបស់ខ្លួន ។ ប៉ុន្តែពួកគេដឹងថាអំពើបាបរបស់ពួកគេធំណាស់ ។ នេះពិបាកខ្លាំងណាស់សំរាប់អ្នកក្រពីព្រោះពួកគេដឹងថា ការធ្វើបុណ្យត្រូវការលុយ ។ របៀបតែមួយគត់ដើម្បីទទួលបានលុយ គឺធ្វើជាមនុស្សដែលមានអំណាច ប៉ុន្តែមនុស្សមានអំណាចជាច្រើនលួចលុយគេ និងមិនមែនជាមនុស្សដែលសុចរិតទេ ។ ពួកគេពុករលួយ ហើយរំលោភបំពានលើអំណាចរបស់ពួកគេ ។ លុយដែលបានទទួលមកតាមរយៈការធ្វើអំពើបាបចំពោះមនុស្សដ៏ទៃទៀតមិនមែនជាលុយសមយកកមធ្វើបុណ្យទេ ។ ដូច្នេះអំពើបាបបន្តទៅទៀត ហើយគ្មាននរណាម្នាក់អាចមានបុណ្យ គ្រប់គ្រាន់ល្មមនឹងដកយកអំពើបាបចេញទេ...លុះត្រាណាតែមានមនុស្ស ដែលគ្រប់លក្ខណ៍ដែលព្រះអង្គអាចមានបុណ្យល្មមសំរាប់ខ្លួនឯង និងមនុស្សដ៏ទៃទៀត ។ វាគួរអោយចាប់អារម្មណ៏ណាស់ដែលនៅក្នុងគម្ពីរសាសនាព្រះពុទ្ធមានពាក្យទំនាយមួយពាក់ព័ន្ធទៅនឹង "ព្រះដ៏បរិសុទ្ធ" ដែលនឹងយាងមកជាព្រះអង្គ ដែលនឹងដឹកនាំមនុស្សចេញពីផ្លូវចាស់ ហើយរស់នៅតាមផ្លូវថ្មី ។

*នៅពេលដែលព្រះពុទ្ធកំពុងតែយាង និងមានព្រះជន្មរសនៅលើពិភពផែនដីនេះ មានបុព្វជិតព្រាហ្មណ៏ម្នាក់ដែលស្លៀកពាក់សំពត់សបានសួរព្រះអង្គថា "តើមនុស្ស និងពួកព្រាហ្មណ៏ទាំងអស់នឹងបន្តធ្វើបុណ្យតទៅទៀតដើម្បីអោយរួចពីលទ្ធផលនៃអំពើបាបដោយរបៀបណា? ព្រះពុទ្ធមានបន្ទូលឆ្លើយតបថា : ទោះបីអ្នកទាំងអស់គ្នាខំធ្វើបុណ្យដាក់ទាន ដោយប្រព្រឹត្តទៅតាមសិក្ខាបទ ទី៥ ទី៨ ទី១០ ឬក៏ទាំង ២២៧ សិក្ខាបទ រយៈពេល ៩ម៉ឺនកោដឆ្នាំ (៩,000,000,000,000 ឆ្នាំ) ឬក៏លើកដៃឡើងប្រណម ដើម្បីនឹងថ្វាយខ្លួនជាយញ្ញបូជាដ៏ដោយ ឬក៏អ្នកបួងសួងដល់ទៅប្រាំដងក្នុងមួយថ្ងៃក៏ដោយ អ្នកទាំងអស់គ្នានៅតែមិនអាចគេចផុតពីលទ្ធផលនៃអំពើបាបរបស់អ្នកទាំងអស់គ្នាបានទេ ប្រសិនបើអ្នកធ្វើបែបនេះរៀងរាល់ថ្ងៃនោះកុសលផលបុណ្យដែលពួកអ្នកបានទទួល គឺគ្រាន់តែស្មើទៅនឹងសក់មួយសសៃរបស់ទារកដែលមិនទាន់កើតប៉ុណ្ណោះ គឺពិតជាតូចខ្លាំងណាស់ អ្នកទាំងអស់គ្នា មិនអាចចូលទៅច្រកទ្វារនៃស្ថានសួគ៌បានទេ ។*

*បុព្វជិតព្រាហ្មណ៏ចាស់នោះបានសួរទៀតថា : តើយើងទាំងអស់គ្នាត្រូវធ្វើដូចម្តេចដើម្បីអោយបាន*

សង្គ្រោះ? ព្រះពុទ្ធមានបន្ទូលឆ្លើយប្រាប់ព្រាហ្មណ៍ចាស់នោះថា ៖ លទ្ធផលនៃអំពើបាប និងកម្មរបស់អ្នកទាំងអស់គ្នា គឺធំធេងខ្លាំងណាស់ ពោលគឺធ្ងន់ជាងផ្ទៃមេឃក្រាស់ជាងផែនដី ហើយខ្ពស់ខ្លាំងណាស់ ដែលរឿងនេះបីដូចជាទេវតាម្នាក់ ដែលបោសសំអាតធូលីសសរនៅតាមជ្រុងនៃបរិវេណប្រាសាទមួយ ជាមួយនឹងក្រណាត់ដែលមានកំពស់កន្លះម៉ែត្រ គឺបោសសំអាតធូលីសសរនោះតែមួយដងទេក្នុងមួយឆ្នាំ រហូតដក់សសរទាំងនេះរិលចុះមកដល់ដី ហើយនៅពេលដែលវារិចសឹកមកដល់ដីនោះហើយ គឺរយៈពេលដែលនឹងចំណាយដើម្បីបញ្ចប់អំពើបាបរបស់អ្នក ។

ព្រះពុទ្ធមានបន្ទូលទៀតថា ៖ ខ្ញុំបានលះបង់នូវឋានៈដ៏ខ្ពង់ខ្ពស់របស់ខ្ញុំ ហើយបានចូលបួសព្រោះខ្ញុំគិតថា ថ្វីបើខ្ញុំជាមនុស្សល្អ ខ្ញុំគ្រាន់តែទទួលបានកុសល្យផលបុណ្យមួយចំនួនតូចប៉ុណ្ណោះ ប្រសិនបើខ្ញុំបានទទួលចំនួននៃកុសល្យផលបុណ្យដូចគ្នារយៈពេល ១០០,000 ជាតិក៏ដោយ ហើយរស់នៅមានរយៈពេលច្រើនជាងពេលមានជីវិត ១០ដងក៏ដោយ ខ្ញុំក៏នៅតែមិនអាចត្រូវបានសង្គ្រោះអោយរួចពីអំពើបាបបានដែរ ។ បុព្វជិតព្រាហ្មណ៍ចាស់នោះបានសួរទៀតថា ៖ ដូច្នេះ តើយើងទាំងអស់គ្នាត្រូវធ្វើដូចម្តេច? ព្រះពុទ្ធមានបន្ទូលឆ្លើយប្រាប់ថា ៖ បន្តធ្វើបុណ្យអ្នកតទៅទៀតទៅ ហើយចូររកព្រះអង្គផ្សេងទៀតដែលនឹងជួយសង្គ្រោះពិភពលោក និងអ្នកទាំងអស់គ្នានៅពេលខាងមុខចុះ ។

ព្រាហ្មណ៍ចាស់នោះបានសួរថា ៖ តើបុគ្គលិកលក្ខណៈរបស់ទ្រង់ដូចម្តេចទៅ? ព្រះពុទ្ធមានបន្ទូលឆ្លើយប្រាប់គាត់ថា ៖ ព្រះដែលនឹងជួយសង្គ្រោះពិភពលោកក្នុងពេលខាងមុខមាន បុគ្គលិកលក្ខណៈដូចនេះ គឺបាតដៃ និងបាតជើងទាំងពីររបស់ទ្រង់ មានសញ្ញាកងចក្រនៅចំហៀងខ្លួន មានរបួសដោយសារគេចាក់ ហើយនៅលើថ្ងាសរបស់ទ្រង់មានគំនូសជាច្រើនដូចសំឡាក ហើយព្រះមួយអង្គនោះនឹងក្លាយទៅជាទូកមាសដែលនឹងនាំអ្នកទាំងអស់គ្នាអោយរួចផុតពីវាលវដ្តសង្សារតាមមធ្យោបាយឆ្ពោះទៅកាន់ឋានសួគ៌ដ៏ខ្ពស់បំផុតមិនចាំបាច់រកមើលការសង្គ្រោះក្នុងផ្លូវចាស់ឡើយ គ្មានការសង្គ្រោះនៅក្នុងផ្លូវចាស់អោយប្រាកដឡើយ បោះបង់វាចោលទៅ ហើយនឹងមានវិញ្ញាណថ្មីមួយដូចជាពន្លឺនៃសត្វអំពិលអំពែក ដែលនឹងចុះពីលើមេឃមកស្ថិតនៅក្នុងចិត្តអ្នកទាំងអស់គ្នា ហើយអ្នកទាំងអស់គ្នានឹងមានជ័យជំនះលើអស់ ពួកមារសត្រូវរបស់អ្នកគ្មាននរណាម្នាក់អាចនឹងបំផ្លាញអ្នកបានឡើយ តែប្រសិនបើអ្នកស្លាប់ អ្នកនឹងមិនត្រលប់មកកើតលើពិភពលោកនេះម្តងទៀតឡើយ អ្នកនឹងធ្វើដំណើរឆ្ពោះទៅកាន់សួគ៌ដ៏ខ្ពស់បំផុតពីស្ថានបរមសុខ ។

**អនុញ្ញាតិអោយថតចំលងគម្ពីរពុទ្ធសាសនា ចេញពីវត្តប្រាលិង ក្នុងខេត្តឈាងម៉ៃ អ្នកដែលបានផ្តល់ការអនុញ្ញាតអោយគឺ លោកប្រាស្រីវិសុតធីវង្ស នៅក្នុងទីក្រុងបាងកក ។ ការថតចំលងនេះត្រូវបានធានាថា ត្រូវបានថតចំលងត្រឹមត្រូវតាមច្បាប់ដើមដកស្រង់ចេញពី សព្វវចនាធិប្បាយសាសនា ខ្សែ២៣ សៀវភៅលេខ២៩ ការស៊ើបសួរនេះធ្វើឡើងនៅ ខែតុលា ទី ១៣ ឆ្នាំ ១៩៥៤ (ព.ស.២៤៩៧) ។**

ព្រះពុទ្ធមានបន្ទូលត្រឹមត្រូវហើយ អំពីភាពឥតប្រយោជន៏នៃការព្យាយាមសន្សំកុសល្យវាមិនអាចទៅរួចទេ ។ ព្រះដ៏បរិសុទ្ធ ដែលព្រះពុទ្ធមានបន្ទូលថានឹងយាងមកនោះ បានយាងមកហើយ ។ ប្រហែលជាប្រាំរយឆ្នាំក្រោយពីព្រះពុទ្ធបានចាកចេញពីពិភពលោកនេះ ពាក្យទំនាយនោះបានសំរេច ។ នៅពេលដែលព្រះយេស៊ូគ្រីស្តបានសុគតនៅលើឈើឆ្កាងដើម្បីដកយកអំពើបាបរបស់មនុស្ស ព្រះហស្ត និងព្រះបាទាទាំងសងខាងរបស់ព្រះអង្គត្រូវបានទំលុះដោយសារដែកគោលធំៗ ដោយបានទុកជារង្វង់មូល (យ៉ូហាន ២០ : ២០) ចំហៀងរបស់ព្រះអង្គត្រូវបានចាក់ទំលុះដោយសារលំពែង (យ៉ូហាន ១៩ : ៣៤) ហើយថ្ងាសរបស់ព្រះអង្គមានស្នាមគំនូសជាច្រើនដោយសារមកុដដែលធ្វើពីបន្លាដែលពួកទាហានរ៉ូមបានបំពាក់អោយព្រះអង្គ (យ៉ូហាន ៩: ២) ។ ព្រះយេស៊ូគ្រីស្តបានបើកផ្លូវថ្មី គឺជាជំនឿដើម្បីមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ដើម្បីអោយផ្លូវចាស់នៃកុសលផលបុណ្យអាចត្រូវបានបោះបង់ចោល ។ តាមរយៈព្រះយេស៊ូតែមួយអង្គប៉ុណ្ណោះ គេអាចរកឃើញការរួចផុតពីការធ្វើបុណ្យ ។ តាមរយៈព្រះយេស៊ូតែមួយប៉ុណ្ណោះ គេអាចរងឃើញការធានាអះអាង ដ៏គ្រប់លក្ខណ៏ថាស្ថានសួគិដ៏ខ្ពស់បំផុតត្រូវបានបើកចំហរ ដោយសារព្រះគុណរបស់ព្រះជាម្ចាស់ ។

---